# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ :...............១៧០............ក.ប/ប្រ.ក

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤

## ប្រកាស
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

### រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានា ដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ ១៩១ សកបយ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា
- បានឃើញប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល
- បានឃើញប្រកាសលេខ ១៥៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល
- បានឃើញលិខិតលេខ ACF ០១៨/១៤ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ របស់នាយកប្រតិបត្តិមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំតែងតាំងអាជ្ញាកណ្តាលសម្រាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលអណត្តិទី ១២

## សម្រេច

**ប្រការ ១ .-** តែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមានសមាសភាពដូចខាងក្រោម ៖

**I-សមាជិកដែលស្នើឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ÷**

១-លោក អាំង អេងថុង

២-លោក គឹម យាត ដារ៉ាវិទ្ធិ

៣-លោក គង់ ផល្លៈ

៤-លោក កុយ នាម

៥-លោក ម៉ែន និម្មិត

៦-លោក ញាន សុមុន្និទ្ធ

៧-លោក ប៉ែន ប៊ុនឈា

៨-លោក រុន សារ៉ាយ

៩-លោក សុខ ម៉ាធឿង

១០-លោក តាំង ទ្រី

**II-សមាជិកដែលស្នើឡើងដោយសមាគមនិយោជក ÷**

១-លោក កៅ ថាច

២-លោក គល់ វឌ្ឍនា

៣-លោក ម៉ារ សំបូរណា

៤-លោក ហែម ហូរណារិទ្ធ

៥-លោក លី តៃសេង

៦-លោក អ៊ុក រី

៧-កញ្ញា យូ សូនទី

៨-លោកស្រី ឈីវ ភិរម្យ

៩-លោកស្រី សេង រួចហ៊ុន

១០-លោក អ៊ឹង សុទ្ធី

**III-សមាជិកដែលស្នើឡើងដោយសហជីព កម្មករនិយោជិត(សហព័ន្ធសហជីព) ÷**

១-លោក លីវ សុវណ្ណា

២-លោក វ៉ែន ពៅ

៣-លោក សុង វណ្ណស៊ីន

៤-លោកស្រី ស៊ីន គីមស៊ាន

៥-លោក ទូន ស៊ីផាន់

៦-ឯកឧត្តម វង្ស វណ្ណា

៧-លោក អន ណន

៨-លោកស្រី អាន វីរៈ

៩-លោក សួង សុផល

១០-លោក ហួន ជុនឌី

**ប្រការ ២ .-** យោងតាមមាត្រា១២ នៃច្បាប់ស្តីពីការងារក្រុមប្រឹក្សាអាជ្ញាកណ្តាល មានភារកិច្ចដូចតទៅៈ-

ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហា ដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុ ជាផលវិបាកផ្ទាល់នៃការវិវាទនេះប៉ុណ្ណោះ។

ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ចំពោះការវិវាទ ដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តបញ្ញត្តិ ច្បាប់ ឬអនុសញ្ញារូមណាមួយ។ ក្រុមប្រឹក្សានេះដោះស្រាយដោយសមធម៌ ចំពោះការវិវាទឯទៀតទាំងអស់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចធំទូលាយ ដើម្បីស៊ើបអំពីស្ថានភាពសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាព ខាងសង្គមកិច្ចនៃកម្មករនិយោជិត ដែលជាសាមីខ្លួនក្នុងការវិវាទ។

ក្រុមប្រឹក្សានេះមានអំណាចអង្កេតគ្រប់បែបយ៉ាងនៅទីកន្លែងសហគ្រាស ឬអង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំង មានអំណាចចាត់ឱ្យភាគីជូនឯកសារ ឬព័ត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬរដ្ឋបាល ដែលមានប្រយោជន៍ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន។ ក្រុមប្រឹក្សានេះ អាចសុំអ្នកជំនាញការជួយបានទៀតផង។

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវលាក់អាថិកំបាំងវិជ្ជាជីវៈចំពោះព័ត៌មាន និង ឯកសារទាំងឡាយ ដែលគេបានជូនមកឱ្យខ្លួនពិនិត្យ និងចំពោះហេតុការណ៍ទាំងអស់ ដែលខ្លួនបានដឹង ក្នុងការបំពេញបេសកកម្មរបស់ខ្លួន។

ការប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវប្រព្រឹត្តទៅដោយបិទទ្វារ។

**ប្រការ ៣**.- កិច្ចដំណើរការ អំណាចយុត្តាធិការ ការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ព្រមទាំងវិធាននៃនីតិវិធី ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ នេះផង។

**ប្រការ ៤**.- សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអាណត្តិមួយឆ្នាំដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០១៤។

**ប្រការ ៥**.- ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជ្រាប "
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
" ដើម្បីអនុវត្ត និងផ្សព្វផ្សាយ "
-អគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
-គ្រប់មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
-គ្រប់សមាគមនិយោជក " ដើម្បីជ្រាប "
-គ្រប់សហព័ន្ធសហជីព " ដើម្បីជ្រាប "
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ " ដើម្បីជួយផ្សព្វផ្សាយ "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ